ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១១ លេខ ៧

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែកក្កដា ឆ្នាំ២០១៨



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) | |
| ១- វគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី | ១-៣ |
| ២- ទស្សនកិច្ចសិក្សាទៅកាន់ប្រទេសកាណាដា ដើម្បីបង្កើនចំណេះដឹង និងដកបទពិសោធ ស្តីពីការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( RIA ) | ៤-៧ |
| II- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០១៨ | ៨-១៦ |
| III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៨ | ១៧-១៩ |

# ១- វគ្គបណ្ដុះបណ្ដាលអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## (Regulatory Impact Assessment Methodology)

## នៅទីស្ដីការគណៈរដ្ឋមន្ត្រី

### ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨



ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី បានបើកវគ្គបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment Methodology) ជូនដល់មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រមាណ ៤០នាក់។

កម្មវិធីបើកវគ្គបណ្ដុះបណ្ដាលនេះ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធាន ECOSOCC និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងគ្រូឧទ្ទេសនាមរួមមាន ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរង ECOSOCC និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងឯកឧត្តម **អេង វត្តមុន្នី** អគ្គលេខាធិការរង ECOSOCC និងជាប្រធានផ្នែកបណ្ដុះបណ្ដាល នៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត។



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាប់ផ្តើមអនុវត្តវិធីសាស្ត្រ RIA សាកល្បងកាលពីឆ្នាំ ២០១៤ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានចាប់ផ្តើមអនុវត្តវិធីសាស្ត្រ RIA សាកល្បងកាលពីឆ្នាំ ២០១៦ ដោយទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ ផ្តើមចេញពីលទ្ធផលនេះ ADB ដែលជាអ្នកផ្តល់មូលនិធិគាំទ្រដល់ការអនុវត្ត RIA បានពង្រីកវិសាលភាពនៃការអនុវត្ត RIA ដោយអញ្ជើញក្រសួង ស្ថាប័ន ចូលរួមអនុវត្តឲ្យបានច្រើន ហើយបានស្នើសុំ ECOSOCC ដើរតួនាទីជាស្ថាប័នបណ្តុះបណ្តាល។

RIA បានក្លាយជាកម្មវិធីមួយដោយបានអនុវត្តសាកល្បងតាំងពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៦ ដែល ECOSOCC ជាអង្គភាពប្រតិបត្តិកម្មវិធី និងមានការចូលរួមអនុវត្តកម្មវិធីដោយក្រសួងចំនួន១៨ ក្រោមហិរញ្ញប្បទានឥតសំណង និងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB។ ដោយការអនុវត្តទទួលបានលទ្ធផលល្អ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

ដើម្បីពង្រឹងសមត្ថភាពមន្ត្រី RIA ក្រុមការងារ RIA នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយក្រុមការងារ RIA នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានស្នើសុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ដែលជាស្ថាប័នបង្គោលក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយវិធីសាស្ត្រ RIA ផ្តល់ការបណ្តុះបណ្តាលអំពី RIA ដល់មន្ត្រីនៃក្រសួងទាំងពីរនេះ។

ការអនុវត្ត RIA ដោយពេញលេញជួយធ្វើឲ្យលិខិតបទដ្ឋានគតិយុត្តមានគុណភាពខ្ពស់ ដែលនាំឲ្យមានអភិបាលកិច្ចល្អ ជំរុញកំណើនសេដ្ឋកិច្ច បង្កើនតម្លាភាពនិងគណនេយ្យភាព កាត់បន្ថយការិយាធិបតេយ្យ

កាត់បន្ថយការជាន់សមត្ថកិច្ចគ្នា កាត់បន្ថយបន្ទុកចំណាយរដ្ឋបាលលើការអនុវត្ត និងកាត់បន្ថយបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ចជាដើម ហើយពិសេសទៅទៀត គឺពង្រឹងជំនឿទុកចិត្តពីសាធារណជន និងធុរជនលើលិខិតបទដ្ឋានគតិយុត្ត។ RIA ទាមទារឲ្យក្រសួងអនុវត្តគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងធ្វើការវាយតម្លៃឲ្យបានហ្មត់ចត់លើផលប៉ះពាល់ ដែលអាចកើតមានឡើងពីបទប្បញ្ញត្តិនានា នៅអំឡុងពេលរៀបចំសេចក្តីព្រាង ដើម្បីជៀសវាង ឬកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមាន ដល់ធុរកិច្ច និងសង្គមទាំងមូល៕



# ២- ទស្សនកិច្ចសិក្សានៅកាន់ប្រទេសកាណាដា ដើម្បីបង្កើនចំណេះដឹង និងដកបទពិសោធ ស្តីពីការអនុវត្តការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត ( RIA )



កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( RIA ) ដែលមានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាអង្គភាពប្រតិបត្តិកម្មវិធី និងមានក្រសួងស្ថាប័ន អនុវត្តកម្មវិធីចំនួន ១៨ គឺក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមនាគមន៍ និងក្រសួងរៀបចំដែនដីនរគរូបណីយកម្មនិងសំណង់ បានអនុវត្តRIA សាកល្បងជាច្រើនឆ្នាំមកហើយ រីឯក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទើបតែចូលរួមអនុវត្តកម្មវិធីបានប៉ុន្មានខែប៉ុណ្ណោះ។ មន្ត្រីថ្មីទាំងនេះបានទទួលការ



បណ្តុះបណ្តាលអំពីវិធីសាស្ត្រRIA បានចប់សព្វគ្រប់អស់ហើយ បច្ចុប្បន្នកំពុងសាកល្បងរៀបចំរបាយការណ៍ RIA។

ដើម្បីបង្កើនគុណភាពចំណេះដឹង និងបទពិសោធក្នុងដំណើរការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងការរៀបចំរបាយការណ៍វាយតម្លៃ ដែលបានជាតុចូលពីការចូលរួមពីភាគីពាក់ព័ន្ធ តាមរយៈកិច្ចពិគ្រោះយោបល់ជាមួយសហគមន៍ និងវិស័យឯកជន ដល់មន្ត្រី ECOSOCC និងមន្ត្រីថ្មីៗរបស់ក្រសួងឲ្យមានគំនិតកាន់តែទូលំទូលាយ។ ដូច្នេះធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំនិងផ្តល់ឋវិកាសម្រាប់មន្ត្រីចំនួន ១១រូប ឲ្យទៅចូលរួមក្នុងទស្សនកិច្ចសិក្សារៀនសូត្រនិងដកបទពិសោធពីការអនុវត្ត RIA នៅប្រទេសកាណាដា។

ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត( Regulatory Executive Team-RET ) បានដឹកនាំគណៈប្រតិភូចំនួន ១១ រូប ក្នុងនោះ ២រូបមកពីក្រុម RET និង ៩រូប មកពីក្រុមការងារ RIA នៃក្រសួង ស្ថាប័នចំនួន ៦ គឺ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើទស្សនកិច្ចសិក្សានៅទីក្រុង Victoria និងទីក្រុង Vancouver ខេត្ត British Columbia នៃប្រទេសកាណាដា ចាប់ពីថ្ងៃទី២០ ដល់៣០ ឧសភា ឆ្នាំ២០១៨ ដើម្បីស្វែងយល់និងដកបទពិសោធស្តីពីការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( RIA )។



ក្នុងរយៈពេល ៩ ថ្ងៃ គណៈប្រតិភូខ្មែរបានជួបពិភាក្សាស្វែងយល់ពីស្ថាប័នរដ្ឋាភិបាល និងឯកជន ចំនួន៨ រួមមាន៖

1. B.C. Ministry of Jobs, Trade and Technology
2. City of Victoria
3. Greater Victoria Chamber of Commerce
4. Ministry of Citizens' Services
5. Federal-Provincial-Territorial Committee on Regulatory Governance and Reform Overview
6. Province of Manitoba-Teleconference
7. Government of Canada-Teleconference
8. International Business Development Division

ជាពិសេសនាថ្ងៃចុងក្រោយ គណៈប្រតិភូ ក៏មានកិត្តិយសបានជួបជាមួយនឹងរដ្ឋមន្ត្រីទទួលបន្ទុកពាណិជ្ជកម្មនៃខេត្ត British Columbia គឺ Honorable George Chow។ ក្នុងឆ្នាំ២០០១ រដ្ឋាភិបាលនៃខេត្ត British Columbia បានដាក់ចេញនូវផែនការកាត់បន្ថយចំនួនកាតព្វកិច្ចដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងទម្រង់ពាក្យស្នើសុំផ្សេងៗឲ្យបានមួយភាគបីក្នុងរយៈ៣ឆ្នាំ។ ជាលទ្ធផលនៃការអនុវត្តផែនការនេះ គឺរដ្ឋាភិបាលបានសម្រេចកាត់បន្ថយចំនួនកាតព្វកិច្ចបានរហូតទៅដល់ជាង ៣៦% លើសផែនការដែលបានកំណត់ ហើយរដ្ឋាភិបាលនៅតែបន្តកាត់បន្ថយចំនួនកាតព្វកិច្ចបានរហូតដល់ ៤៣%។

ដើម្បីងាយស្រួលក្នុងការដាក់ចេញផែនការកាត់បន្ថយចំនួនកាតព្វកិច្ចដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងទម្រង់ពាក្យស្នើសុំផ្សេងៗ (ឬហៅថា ការកាត់បន្ថយការិយាធិបតេយ្យ-





Red Tape Reduction ) រដ្ឋាភិបាលបានដាក់បទបញ្ជាដល់ក្រសួង ស្ថាប័នទាំងអស់រាប់ចំនួនកាតព្វកិច្ច ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងទម្រង់ពាក្យស្នើសុំផ្សេងៗក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទាំងនោះ ដើម្បីបង្កើតតួលេខមូលដ្ឋាន។

ដើម្បីធានាមិនឲ្យមានការបង្កើតចំនួនកាតព្វកិច្ចថ្មីៗ បន្ទាប់ពីបានកាត់បន្ថយអស់ ៤៣% រដ្ឋាភិបាលបានដាក់គោលការណ៍ថា ប្រសិនបើចាំបាច់បង្កើតកាតព្វកិច្ចថ្មីមួយ គឺត្រូវលុបកាតព្វកិច្ចដែលមានស្រាប់មួយចេញវិញ៕

# II- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០១៨



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំឆមាសទី១ ឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡បើប្រៀបធៀបក្នុងឆមាសទី១ដូចគ្នាឆ្នាំ២០១៨និងឆ្នាំ២០១៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង២,៥% ដែលអាចចាត់ទុកថា ជាកម្រិតទាបបើធៀបនឹងការចែងក្នុងគោលនយោបាយ (៣% - ៥%)។

តារាង១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០១៦ដល់ឆ្នាំ២០១៨

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា$^{P}$ | សីហា$^{P}$ | កញ្ញា$^{P}$ | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ខែដូចគ្នាឆ្នាំ | ២,០% | ២,៣% | ២,៣% | ២,៧% | ២,៩% | ២,៩% | ៣,១% | ២,៨% | ២,៧% | | | | |
| ២០១៧ | ខែដូចគ្នាឆ្នាំ | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៩% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| ២០១៦ | ខែដូចគ្នាឆ្នាំ | ៣,០% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣,០% |

P:តួលេខខែ កក្កដា សីហា កញ្ញា និងប្រចាំឆ្នាំ២០១៨ ជាតួលេខព្យាករណ៍(តាមវិធីសាស្រ្ត **Decomposition**)

តារាង១.២. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (តាមក្រុមទំនិញ)

| ក្រុមទំនិញ | សន្ទស្សន៍មធ្យមឆមាសទី១ ឆ្នាំ២០១៨ | សន្ទស្សន៍មធ្យមឆមាសទី១ ឆ្នាំ២០១៧ |
|---|---|---|
| ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១៧៣,១% | ១៦៨,៩% |
| ម្ហូបអាហារ | ២១៣% | ២០៨,០% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១៦១,១% | ១៥៩,៧% |
| សម្លៀកបំពាក់ និងស្បែកជើង | ១៤៦,២% | ១៤៣,៩% |
| ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ននិងឥន្ទនៈផ្សេងទៀត | ១២៥,៧% | ១២៣,៩% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ១៥០,៦% | ១៥០,២% |
| សុខាភិបាល | ១៣៤,៦% | ១៣២,៧% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | |
|---|---|---|
| ការដឹកជញ្ជូន<br>ក្នុងនោះ ប្រេងសាំង | ១១៦,៥%<br>៩៨,០% | ១១២,៥%<br>៩០,០% |
| ទូរគមនាគមន៍ | ៦៧,៧% | ៦៨,៣% |
| ការកម្សាន្ត និងវប្បធម៌ | ១១៧,៩% | ១១៩,២% |
| ការសិក្សា | ១៥៩,២% | ១៦០,១% |
| ភោជនីយដ្ឋាន | ២៦៥,៧% | ២៥០,៥% |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៤៤,៥% | ១៣៩,៦% |

កំណត់សម្គាល់ : គ្រាគោលគឺត្រីមាសទី៤ ឆ្នាំ២០០៦ = ១០០%

➢មុខទំនិញដែលឡើងថ្លៃខ្ពស់មានប្រេងសាំង ៨,១% ឧស្ម័ន ៧,៤% ប្រេងម៉ាស៊ូត ៦,៦% និងត្រីស្រស់ ៤,៨% ។

➡**អត្រាប្តូរប្រាក់** : ជារួមអត្រាប្តូរប្រាក់មានស្ថេរភាព។ ប្រាក់រៀលមានការឡើងថ្លៃធៀបនឹងដុល្លារនិងដុង ប៉ុន្តែមានការធ្លាក់ថ្លៃធៀបនឹងប្រាក់បាត។

| ប្រភេទ | ចុងឆមាសទី១/២០១៨ | ចុងឆមាសទី១/២០១៧ | បម្រែបម្រួល |
|---|---|---|---|
| **៛/១ដុល្លារ** | ៤០៦៣៛ | ៤០៨៦៛ | -០,៦% |
| **៛/១បាត** | ១២៣៛ | ១២០៛ | ២,៥% |
| **៛/១ដុង** | ០,១៧៧៛ | ០,១៨០៛ | -១,៧% |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០១៨ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន ៩៥៨៨,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន២ ៣៩៧,២លានដុល្លារ ស្មើនឹង៥៤% នៃផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ ចំណូលចរន្តមានចំនួន ៩ ៣៧០ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន២ ៣៤២,៨លានដុល្លារ ស្មើនឹង ៥៤% នៃផែនការ និងចំណូលមូលធនចំនួន ២១៩ប៊ីលានរៀល។

➢បើធៀបនឹងឆមាសទី១ដូចគ្នា ចំណូលថវិកាជាតិកើនឡើង១១% ដែលក្នុងនោះ៖ ចំណូលចរន្តកើនឡើង១៣%។

➢ ក្នុងចំណូលចរន្ត :ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន ៨៤០៣,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន២ ១០០,៨លានដុល្លារ ស្មើនឹង ៥៦% នៃផែនការប្រចាំឆ្នាំ។ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧ចំណូលសារពើពន្ធកើនឡើង ១៣% ដែលក្នុងនោះ ពន្ធនិងអាករគយ កើនឡើង ៣៥% (តាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករ កើនឡើង២៩%) និងចំណូលពន្ធដារ ថយចុះ ៧% (តាមអគ្គនាយកដ្ឋានពន្ធដារ ថយចុះ៣%) ។

ក្រាហ្វ ២.១. សមាសធាតុចំណូលសារពើពន្ធ តាមឆមាស (២០១៤-២០១៦)



តារាង២.១. សមាសភាពនៃចំណូលចរន្ត

| មុខចំណូល | អនុវត្តផែនការ | %Δធៀបនឹងឆ. ១ឆ្នាំ២០១៧ | **មុខចំណូល** | អនុវត្តផែនការ | %Δធៀបនឹងឆ.១ឆ្នាំ២០១៧ |
| --- | --- | --- | --- | --- | --- |
| **ចំណូលសារពើពន្ធ(រតនាគារ)** | ៥៦% | +១៣% | **ចំណូលមិនមែនសារពើពន្ធ** | ៣៧% | +១% |
| ✓ពន្ធនិងអាករគយ(**អ.នាគយនិងរដ្ឋាករ**) | ៦៨% | +២៩% | ✓កាស៊ីណូ | ៣៩% | –៩% |
| -ពន្ធគយ (របបនាំចូល) | ៥១% | +១៦% | ✓អាជ្ញាបណ្ណក្នុងស្រុក | ៥២% | +៣២% |
| -អាករពិសេសលើរបបនាំចូល | ៨៦% | +៣៩% | ✓កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ១០% | –៦៦% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | ៦១% | +២៧% | ✓នេសាទ | ១៩% | –៤៦% |
| -អាករនាំចេញ | ៤៩% | +៣២% | ✓ រុក្ខាប្រមាញ់ | ៣៧% | –៤៩,៩% |
| -អាករបន្ថែមលើផលិផលគេលសិលា | ៥២% | +២% | ✓សម្បទានរ៉ែ | ៣៦% | +១០៧,៩% |
| ✓ ចំណូលពន្ធដារ(**អ.នា ពន្ធដារ**) | ៥៥% | –៣% | ✓អាកាសចរណ៍ស៊ីវិល | ៤៥% | –១៥,២% |
| -ពន្ធលើប្រាក់បៀវត្ស | ៤៨% | +១៤% | ✓ ផលទុនទេសចរណ៍ | ៥២% | +០,៣% |
| - ពន្ធលើប្រាក់ចំណេញ | ៦៧% | –៣% | ✓ត្រួតពិនិត្យគុណភាពផលិតផល | ៣% | –១% |
| - អាករលើតម្លៃបន្ថែម | ៤៨% | –១៨% | ✓ ជួលសហគ្រាស សម្ភារៈ | ២០% | –៤៩% |
| -អាករពិសេស | ៥៧% | +១០% | ✓ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | % | –៦៦% |
| -ចំណូលផ្សេងៗ | ៥៣% | +១០% | | | |
| -ថវិកាខេត្ត–រាជធានី | ៥៧% | +៥១% | | | |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ឆ្នាំ២០១៨ អនុវត្តបានចំនួន៦ ៧៤៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន១៦៨៦,២ លានដុល្លារ ស្មើនឹង ៣៦% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ ចំណាយចរន្តសម្រេចបានចំនួន៥ ៩៥៨,៧ប៊ីលានរៀល ស្មើនឹង ៣៩% នៃផែនការ និងចំណាយមូលធនមានចំនួន ៧៨៦,៣ប៊ីលានរៀល។

➢បើប្រៀបធៀបឆមាសទី១ដូចគ្នាឆ្នាំ២០១៧ ចំណាយថវិកាជាតិ កើនឡើង១៩% ក្នុងនោះ ចំណាយចរន្ត កើនឡើង១៩% និងចំណាយមូលធន កើនឡើង១៧,៩% ។

➢ថវិកាជាតិនាឆមាសទី១ឆ្នាំ២០១៨ មានអតិរេកចំនួន ២៨៤៣,៨ប៊ីលានរៀល ស្មើនឹង ៧១០,៩លានដុល្លារ ស.រ.អា។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៨មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ M2 មានចំនួន៧៩ ៣៤៨ប៊ីលានរៀល កើនឡើង ២២% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៧។

➢ការកើនឡើងនៃ M2 នេះបណ្ដាលមកពីកំណើននៃរូបិយវត្ថុក្រៅធនាគារ១៨% ប្រាក់បញ្ញើចរន្ត ៥% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ២០% និងប្រាក់បញ្ញើជារូបិយបណ្ណ ២២%។

➢ចំនួនប្រាក់រៀលនៅក្នុងនិងក្រៅធនាគារសរុបមានចំនួន ១៥,៤% នៃរូបិយវត្ថុ M2 រីឯប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៦%។

ក្រាហ្វ៣.សមាសធាតុរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៨



➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន ៨ ៩៨៥លានដុល្លារកើនឡើង១៦% ធៀបនឹងឆមាសទី១ឆ្នាំ ២០១៧ ➢**ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា** ជាទូទៅមានការកើនឡើង ដោយក្នុងឆមាសទី១ឆ្នាំ២០១៨ មានចំនួន ២៨ ៨៣៧,១ប៊ីលានរៀល កើនឡើង ២១% បើធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ ២០១៧។

➢**ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ** មានចំនួន ៧៤ ២៨៣,៦ប៊ីលានរៀល កើនឡើង ១៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៧។

➢**ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** (មិនទាន់មានទិន្នន័យ)

➢***អត្រាការប្រាក់ប្រចាំឆ្នាំ***

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០១៨ | ចុងឆមាសទី១ ឆ្នាំ២០១៧ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៩% | ៦,០៣% | -០,៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៤% | ៤,៤១% | ១% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៣៩% | ១៤,៤៨% | -២១% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៣២% | ១១,៨០% | -៤% |
| កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ០% |
| កម្ចីជារៀលនៅហត្ថកសិករ | ១៨% | ១៨% | ០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៥,៧% | ១៨% | -១៣% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

ក្នុងឆមាសទី១ ឆ្នាំ២០១៨ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម :

➡កសិកម្ម

➢តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំផ្សេងៗ ឆ្នាំ ២០១៦ ២០១៧ និង៦ខែដើមឆ្នាំ២០១៨។

| *ប្រភេទដំណាំ* | *ឆមាសទី១-២០១៨* | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ១៤៩៥ | ២៦៥៨ | ២៦០០ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ១៤៥,៨ | ២០៧,២ | ១១៦ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៥១៥,៤ | ៥៥៨,៧ | ៦៥២ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | ១,៥ | ៣,៣ | ៣,៤ |
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | ២២,៤ | ៣០,៧ | ២៧,៣ |
| ផ្ទៃដីដាំសណ្តែកបាយ (ពាន់ហិកតា) | ២៦,០ | ៣៣,៥ | ៣៧,៦ |
| ផ្ទៃដីដាំសណ្តែកដី (ពាន់ហិកតា) | ៧,៩ | ១២,៥ | ១២,៥ |
| ផ្ទៃដីដាំសណ្តែកសៀង (ពាន់ហិកតា) | ៨,៨ | ៤០,២ | ៤២ |
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា)<br>ក្នុងនោះ: ផ្ទៃដីចៀរជ័រ | ៤៣៦,៣<br>១៧៣,០ | ៤៣៦,៣<br>១៧០,២ | ៤៣២,៧<br>១២៧ |

➢ ផលិតផលនេសាទមានចំនួន ៣១៩ **ពាន់តោន** កើនឡើង ៦% បើធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០១៧។

➡ឧស្សាហកម្ម

➢ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៤៤៧៤,២ GWh កើនឡើង២០% ធៀបនឹងឆមាសទី១ឆ្នាំ២០១៧។ ក្នុងនោះវារីអគ្គិសនីមានចំនួន ១៦៣៦ GWh កើនឡើង៥៦% អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១៩១២,៧GWHកើនឡើង២% អគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ១៩០,៣ GWh កើនឡើង ២១% និងអគ្គិសនីនាំចូលពីប្រ ទេសជិតខាងដោយEDCមានចំនួន ៧៣៥,៣ GWH កើនឡើង ១៥% ។

➢ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៧៦៧,២លានដុល្លារ កើនឡើង ១៣% ធៀបនឹងឆមាសទី១ឆ្នាំ២០១៧។

➢ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម:

| ប្រភេទ | ចំនួន :ឆមាសទី១ ឆ្នាំ២០១៨ | ចំនួន:ឆមាសទី១ ឆ្នាំ២០១៧ | បម្រែបម្រួល |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | ៧៤ | ៤៦ | +៦១% |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៩៨ | ១៦២១ | -១% |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ៧៧ | ១១២ | -៣១% |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បន្ត) | ១៥៩ | ១៥២ | +៥% |

➡**សំណង់**

➢សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៥ ៣៥៣,៦ពាន់ម² ថយចុះ២៧%បើធៀបនឹងឆមាសទី១ ឆ្នាំ២០១៧។ ការអនុញ្ញាតនេះ ជាទឹកប្រាក់មានចំនួន ២ ១៥៣,៦លានដុល្លារ ថយចុះ៥៦%បើធៀបនឹង៦ខែដើមឆ្នាំ២០១៧។ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន :

| *ប្រភេទសំណង់* | ពាន់ម² :ឆមាសទី១ ឆ្នាំ២០១៨ | ពាន់ម² :ឆមាសទី១ ឆ្នាំ២០១៧ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ២២៩១,៣ | ៣៩៤៩,៤ | -៤២% |
| ឧស្សាហកម្ម | ៣២២,៤ | ៣៨៤,៧ | -១៦% |
| ពាណិជ្ជកម្ម | ៥០៤,៣ | ២៥៧៨,៣ | -៨០% |
| ទេសចរណ៍ | ២១០៣,៣ | ៣៥៥,៨ | +៤៩១% |
| ... | | | |
| អនុញ្ញាតសរុប | ៥៣៥៣,៦ | ៧២៨៤,៧ | -២៧% |

➢ **ដូច្នេះ** ក្នុងការអនុញ្ញាតឆមាសទី១ ឆ្នាំនេះ សំណង់ដែលពេញនិយមគឺលំនៅឋាន (៤២,៨% នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (៣៩,២៩% នៃផ្ទៃក្រឡាសរុប)។

➡**ការងារ**

| ប្រភេទ | ឆមាសទី១ ឆ្នាំ ២០១៨ (នាក់) | ឆមាសទី១ ឆ្នាំ ២០១៧ (នាក់) | បម្រែប ម្រួល |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារមុខរបរ និងការងារ) | ៨០៤៦ | ៧៧៤៣ | +៤% |
| អ្នកទទួលបានការធ្វើតាមរយៈក្រសួងនិងក្រុមហ៊ុន | ៩៥៤៦២ | ៨៧៨៦៨ | +៩% |
| អ្នកទទួលបានការធ្វើក្នុងប្រទេស | ៦៧០៨៤ | ៦៩៩១៦ | -៤% |
| អ្នកទទួលបានការធ្វើក្រៅប្រទេស | ២៨៣៧៨ | ១៧៩៥២ | +៥៨% |

## ➡វិនិយោគ

➢គម្រោងវិនិយោគ**អនុញ្ញាតដោយ** ក.អ.ក. (ថ្មី និងពង្រីក)

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៨ | ឆមាសទី១ ឆ្នាំ២០១៧ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ៣៤៦៨,៩ | ៣០៣៦,៨ | +១៤% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣៣៧,៨ | ១៩០,៦ | +៧៧% |
| វិស័យឧស្សាហកម្ម | ៨៤៧,៤ | ៦៩៨,៩ | +២១% |
| ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេស | ៤៧៨,៥ | ៣៣៧,៥ | +៤២% |
| វិស័យទេសចរណ៍ | ២០១,១ | ៦៤៧,៨ | -៦៩% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២០៨២,៦ | ១៤៩៩,៥ | +៣៩% |
| **គម្រោងថ្មី និងគម្រោងពង្រីក** (ចំនួន) | ១០៦,០ | ៨៧,០ | +២២% |
| **បង្កើតការងារ** (ពាន់នាក់) | ៩៨,៦ | ១១៩,១ | -១៧% |

## ➡សេវាកម្ម និងទេសចរណ៍

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី :

| *ប្រភេទ* | *ចំនួន* :ឆមាស១ ឆ្នាំ ២០១៨ | *ចំនួន* :ឆមាស១ ឆ្នាំ ២០១៧ | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៥៧៦៦ | ២១៩០ | +១៦៣% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៦៦ | ២០ | +២៣០% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ៣០៣៩ | |

➢**ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប៥កំពង់ផែ)មានចំនួន៦ ៤៥៤,២ពាន់តោន កើនឡើង២៦%ធៀបនឹងឆមាសទី១ ឆ្នាំ២០១៧។ ក្នុងនោះ :

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៨ (ពាន់តោន) | ឆមាសទី១ឆ្នាំ២០១៧(ពាន់តោន) | បម្រែបម្រួល |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ១៤៩២,១ | ១៣២២,៧ | +១៣% |
| កំពង់ផែកំពង់សោម | ៣៩៦៧,៩ | ៣៣៧៨,៦ | +១៧% |
| កំពង់ផែស្រែអំបិលនិងកោះកុង | ១១២,៣ | ៦៤,៨ | +៧៣% |
| កំពង់ផែឧកញ៉ាម៉ុង | ៤០៨,៨ | ៣៤៣,៨ | +១៩% |

## ➥អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៨(ពាន់នាក់) | ឆមាសទី១ ឆ្នាំ២០១៧(ពាន់នាក់) | *បម្រែបម្រួល* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១១២,៤ | ១១៥,៩ | -៣% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣២៤,៧ | ២៦៦,៩ | +២២% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៥៩៥,៥ | ៣៦៧៦,១ | +២៥% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៩៦៤,៣ | ៨៤២,០ | +១៥% |
| អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | ៣០០០,៨ | ២៦៦២,៤ | +១៣% |
| ✓តាមផ្លូវអាកាស | ២០០៤,១ | ១៦០៥,៧ | +២៥% |
| ✓ តាមផ្លូវគោក និងទឹក | ៩៩៧,៥ | ១០៥៦,៧ | -៦% |

### ➤ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៨ | ឆមាសទី១ ឆ្នាំ២០១៧ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១១០,០ | ១០១,៩ | ៨% |
| ក្នុងនោះទទួល | ១៤,២ | ១៣,៨ | ៣% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៦១៤,៦ | ៦៤៦,២ | -៥% |
| ក្នុងនោះទទួល | ៣១០,២ | ៣២៦,៨ | -៥% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១១៥១៩,២ | ១៤ ៦០៦ | -២១% |
| ក្នុងនោះហៅចូល | ៣៤៣៣,៨ | ៤២៦២,៣ | -១៩% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៤១២៤០,៥ | ៥៧ ៩០៥,៥ | -២៩% |
| ក្នុងនោះហៅចូល | ៤០៦២៥,១ | ៥៧ ៤៩៥,២ | -២៩% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ:

➡ការនាំចូលក្នុងឆមាសទី១ ឆ្នាំ២០១៨មានចំនួន ៣១ ១១៩ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៧ ៧៧៩,៨ លានដុល្លារ កើនឡើង ១៣% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៧។ក្នុងនោះមុខទំនិញគួរកត់សម្គាល់មាន:

| បរិយាយ | %Δធៀបនឹងឆ.ទី១ ឆ្នាំ ២០១៧ | បរិយាយ | %Δធៀបនឹងឆ.ទី១ ឆ្នាំ ២០១៧ |
|---|---|---|---|
| ប្រេងសាំង | +១០% | គ្រាក់ទ័រនិងគោយន្ត(ជាគ្រឿង) | +៤% |
| ប្រេងម៉ាស៊ូត | -០,៥% | ម៉ូតូ(ជាគ្រឿង) | +២១% |
| ឧស្ម័ន | +១១% | អង្ករ | +៥០០% |
| ប្រេងខ្មៅ | +៩% | ផ្លែឈើនិងបន្លែ | -៣៨% |
| អគ្គិសនីនាំចូល | +១៥% | ជីនិងថ្នាំកសិកម្ម | +០,២% |
| ដែកសំណង់ | +២១% | បារី | +២៩% |
| ស៊ីម៉ង់ត៍ | +១៨% | ភេសជ្ជៈ | +៣៩% |
| គ្រឿងអេឡិចត្រូនិក | +២៣៨% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៩% |
| រថយន្តសរុប (ជា ព.ល.រ) | +១១% | | |
| រថយន្តសរុប (ជាគ្រឿង) | +១២% | | |

➡**ការនាំចេញ** ក្នុងឆមាសទី១ឆ្នាំ២០១៨ មានចំនួន ២៣ ៥០៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៥ ៨៧៦,២លានដុល្លារ (មានចំនួន៧៥,៥%នៃការនាំចូល) មានការ កើនឡើង ៩% ធៀបនឹងឆមាសទី១ ឆ្នាំ ២០១៧។ ក្នុងនោះ មុខទំនិញ សំខាន់ៗមួយចំនួនមានេនាះ៖

| ទំនិញ | %Δធៀបនឹងឆ.ទី១ ឆ្នាំ២០១៧ | ទំនិញ | %Δធៀបនឹងឆ.ទី១ ឆ្នាំ២០១៧ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១១% | ផលិតផលនេសាទ | +៩០% |
| វាយនភណ្ឌនិងស្បែកជើង | +១៧% | កៅស៊ូ | -២% |
| អង្ករ | -១% | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆមាសទី១ ឆ្នាំ២០១៨សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោមៈ

| ល.រ. | សូចនាករ | % Δ ធៀបនឹងឆមាស១ ឆ្នាំ២០១៦ | កំណត់សម្គាល់ |
|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | +៨,១% | |
| ២ | ថ្លៃឧស្ម័ន | +៧,៤% | |
| ៣ | សំណាង់អនុញ្ញាត(តាមផ្ទៃក្រឡា) | -២៧% | |
| ៤ | សំណាង់អនុញ្ញាត(តាមសាច់ប្រាក់) | -៥៦% | |
| ៥ | ការនាំចូលផ្លែឈើនិងបន្លែ | -៣៨% | |

## ៧) សេចក្តីសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោមៈ*

១) ធុរកិច្ចក្នុងប្រទេសកម្ពុជាគ្រប់ខ្នាតមានការប្រឈមនឹងថ្លៃខ្ពស់នៃការដឹកជញ្ជូន និងឡជីស្ទីកដែលតម្រូវឲ្យមានការសិក្សា ពិគ្រោះយោបល់ វាយតម្លៃ និងកំណត់អាទិភាពគោលនយោបាយ ក្នុងរយៈពេលខ្លី មធ្យម និងវែង ក្នុងគោលដៅលើកកម្ពស់ចីរភាពនៃកំណើនសេដ្ឋកិច្ច។ ថ្លៃខ្ពស់នៃឡជីស្ទីក ដែលរងឥទ្ធិពលពីការត្រួតគ្នានៃមុខងារភារកិច្ចរបស់ស្ថាប័ន រួមទាំងកត្តាដទៃទៀតដូចជា ថ្លៃអគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធ កង្វះខាតកម្មករជំនាញ កង្វះខាតតម្លាភាព កង្វះខាតវត្ថុធាតុដើមដើម្បីផ្គត់ផ្គង់សង្វាក់ផលិតកម្ម ធ្វើឲ្យចរាចរណ៍ទំនិញ និងការធ្វើធុរកិច្ចមានតម្លៃខ្ពស់។

២) ក្នុង៦ខែដើមឆ្នាំ ២០១៨នេះ ទឹកជំនន់បានបង្កការខូចខាតដល់ផ្ទៃដីដាំស្រូវចំនួន ៣១៧៨ ហិចតា។

៣) ក្នុងឆមាសទីមួយឆ្នាំ២០១៨នេះ តួលេខនាំចូលបន្លែមានការថយចុះគួរជាទីចាប់អារម្មណ៍ ដែលអាចបណ្តាលមកពីក្តីបារម្ភរបស់ប្រជាពលរដ្ឋអំពីសារធាតុគីមីពុលដែលមានក្នុងបន្លែនាំចូល និងការដាំដុះបន្លែផ្លែឈើក្នុងស្រុកកើនឡើង៕



រូបភាពនៃកិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា



## III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៧/១៨<br>ម៉ោង០៧:៣០នាទី | ចូលរួមកិច្ចប្រជុំបន្តត្រួតពិនិត្យការអនុវត្តផែនការការងារគណបក្សដែលបានដាក់ចុះកន្លងមក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ២ | ០២/០៧/១៨<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការស្ពានអាកាសមិត្តភាពកម្ពុជា-ចិន សែនសុខ ប្រវែង៩៤២ម៉ែត្រ ក្រោមហិរញ្ញប្បទានសម្បទាន ពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ |
| ៣ | ០៤/០៧/១៨<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិព្រៃរកា ឃុំឆកឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល។ |
| ៤ | ០៥/០៧/១៨<br>ម៉ោង០៧:០០នាទី | បន្តចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិព្រៃរកា ឃុំឆកឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល។ |
| ៥ | ០៧/០៧/១៨<br>ម៉ោង០៨:៣០នាទី | ចូលរួមជាសហាធិបតី ក្នុងពិធីបើកយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៦ | ០៧/០៧/១៨<br>ម៉ោង១៤:៣០នាទី | ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពី ឯកសារសម្រាប់ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ នៃរដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ៧ | ០៩/០៧/១៨ **ម៉ោង១៥:៣០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីចុះឃោសនាគោលនយោបាយគណបក្សនៅមូលដ្ឋានឃុំតាំងយ៉ាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅទីស្នាក់ការគណបក្សឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៨ | ១០/០៧/១៨ **ម៉ោង១០:៣០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីចុះឃោសនាគោលនយោបាយគណបក្សនៅមូលដ្ឋានឃុំព្រៃល្វា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃ គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅទីស្នាក់ការគណបក្សឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៩ | ១០/០៧/១៨ **ម៉ោង១៥:៣០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីចុះឃោសនាគោលនយោបាយគណបក្សនៅមូលដ្ឋានឃុំក្តាញ់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃ គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅទីស្នាក់ការគណបក្សឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១០ | ១៤/០៧/១៨ **ម៉ោង០៨:៣០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយមេគ្រួសារបក្សក្នុងឃុំអង្កាញ់ នៅទីស្នាក់ការគណបក្សឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១១ | ១៤/០៧/១៨ **ម៉ោង១០:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយមេគ្រួសារបក្សក្នុងឃុំព្រៃកប្បាស នៅវត្តព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១២ | ១៥/០៧/១៨ **ម៉ោង១៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួប១០ឆ្នាំ ប្រាសាទព្រះវិហារ និងខួប១ឆ្នាំ តំបន់ប្រាសាទសំបូរព្រៃគុក ចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ។ |
| ១៣ | ១៧/០៧/១៨ **ម៉ោង១០:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុខជាតោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | **២០/០៧/១៨ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៣/០៧/១៨ ម៉ោង១៥:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **កែវ រ៉េមី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៧/០៧/១៨ ម៉ោង០៨:៣០នាទី** | ចូលរួមជាសហាធិបតី ក្នុងពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១៧ | **២៧/០៧/១៨ ម៉ោង១៤:៣០នាទី** | ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in